# ទង់ព្រះពុទ្ធសាសនា

ទង់ ព្រះពុទ្ធសាសនាបានធ្វើការបង្ហាញរូបរាង និងចាប់បង្ហួតនៅក្នុងប្រទេសខ្មែរ គឺ: នាឳកាសបុណ្យពាក់កណ្ដាលសាសនា ក្នុងពុទ្ធសករាជ២៥០០នៅទីក្រុងភ្នំពេញគឺក្រោយពេលដែល សម្ដេចព្រះសង្ឃរាជ ជួន ណាត យាងមកពីប្រជុំមហាសន្និបាតប្រមុខដឹកសង្ឃពុទ្ធសាសនា ទូទាំងពិភពលោក នាប្រទេសឥណ្ឌា រួចនោះ។

ទង់ព្រះពុទ្ធសាសនា មានប្រាំពណ៌ ហើយពណ៌នីមួយៗ តំណាងព្រះរាជសកម្មភាពព្រះសម្មាសម្ពុទ្ធ និងផ្ដល់ជាគតិអប់រំដល់ពុទ្ធសានិកដូចតទៅ:

* ពណ៌ខៀវ តំណាងអោយព្រះរាជសកម្មភាពព្រះពុទ្ធ កាលទ្រង់ស្ម័គ្រ ព្រះទ័យឆ្កៀលព្រះនេត្រទាំងសងខាង បូជាថ្វាយដល់ឥន្ទព្រាហ្មណ៍ ដើម្បីប្រាថ្នាការត្រាស់ដឹង ។

តាមរយ:ពណ៌ខៀវ តំណាងព្រះរាជសកម្មភាពនេះ គឺចង់អប់រំទូន្មានពុទ្ធសាសនិកទាំងអស់ឲ្យ មានភាពជ្រះថ្លាហ៊ានលះបង់វត្ថុជាទីស្រលាញ់ដើម្បីជួយសង្គ្រោះជន ស្រោចស្រង់មនុស្សពីអន្លង់ទុក្ខ  ពីអន្លង់អវិជ្ជា ឆ្ពោះទៅកាន់ ទីបរមសុខ។

* ពណ៌លឿង តំណាងព្រះរាជសកម្មភាពព្រះពុទ្ធ ដែលទ្រង់បានពន្លះសាច់សម្រក់ឈាមរបស់ព្រះអង្គឲ្យដល់ឥន្ទ្រព្រាហ្មណ៍ ដើម្បីបំពេញសាច់ខ្វះខាត និងលាបលន តុបតែងលំអរបង្គ្រប់សាច់បដិមាពុទ្ធអង្គ ដែលខ្វះចន្លោះ បំណងសម្រេចការត្រាស់ដឹង ។

តាមរយ:ពណ៌តំណាងព្រះរាជសកម្មភាពនេះ គឺចង់បណ្ដុំបណ្ដាលកម្លាំង សទ្ធាដល់ ពុទ្ធបរិសទ្ធឲ្យរួមគ្នា បរិច្ចាគអ្វីៗដែលខ្លួនមាន ដើម្បីរួមចំណែកកសាងបដិមាស្ទួងព្រះពុទ្ធអង្គ សម្រាប់ទុកជាទីសក្ការ:បូជាតរៀងរហូតទៅ ។

* ពណ៌ក្រហម តំណាងកាល ដែលព្រះពុទ្ធស្ម័គ្រ ព្រះហាទ័យពុះទ្រូងរូង យកថ្លើមនិងឈាមតាមការចង់បានរបស់ពេទ្យហ្ម ដើម្បីយកទៅបឺតស្រូបពិសពស់ពីព្រោះព្រះមាតាដែលត្រូវពស់អសិរពិស ចឹក ហើយតម្រូវត្រង់ឱសថ  បែបនេះ

ទើបសង្គ្រោះអាយុជីវិតព្រះមាតាព្រះអង្គបាន ។

តាមរយៈពណ៌ ព្រះរាជសកម្មភាពនេះ គឺជាការផ្តល់ដំបូន្មានពុទ្ធបរិស័ទ្ធ ត្រូវមាន សន្តានចិត្តតបគុណមាតាបិតាដែលជា " ព្រះរស់" អោយបានល្អទោះបីជាខ្លួនត្រូវលះបង់ជីវិតក៏ដោយ។

* ពណ៌គ្រាប់ខ្នុរ ឬ ហង្សបាទ តំណាងព្រះរាជសកម្មភាពព្រះពុទ្ធសម្រេចព្រះទ័យប្រគល់ជីវិតអោយយក្សស៊ី ប្តូរនឹងជីវិតមាតាដែលយក្សចង់ស៊ី ឲ្យលោកមានជីវិតរស់រានតទៅទៀត។

តាមរយៈពណ៌តំណាងព្រះរាជសកម្មភាពនេះ គឺចង់ធ្វើការអប់រំពុទ្ធសាសនិកឲ្យមានចិត្តកតញ្ញូកតវេទីចំពោះ មាតាបិតា តាមរយៈការផ្គត់ផ្គង់ ទំនុកបម្រុងបាយទឹកជូនលោកទាំងពីរ អោយបានឆ្អែតឆ្អល់មិនខ្លួនជាប្រចាំ។

* ពណ៌ស តំណាងព្រះរាជសកម្មភាពព្រះពុទ្ធ កាលដែលព្រះអង្គយោងយកកំណើតជាព្រះវេស្សន្ត  ពេលនោះទ្រង់បានប្រទានដំរីស បច្ច័យនាគជាដំរីមង្គលនគរស្រីពិរាស្ត្រ ទៅឲ្យអ្នកស្រុក កលិង្គរាស្ត្រ ដើម្បីជួយស្រោចស្រង់រាស្ត្រនគរនោះពីការរាំងស្ងួតពីទុរភិក្ស។

តាមរយៈពណ៌តំណាងព្រះរាជសកម្មភាពនេះ គឺចង់អប់រំ ពុទ្ធបរិស័ទ្ធឲ្យមានចិត្តចែករំលែក សេចក្តីសុខផ្ទាល់ខ្លួនដល់អ្នកស្រុកដ៏ទៃ ក្រៅពីជាតិខ្លួន  សម្រាប់ឲ្យពួកគេមានលិទ្ធភាពអាចរស់នៅសុខសាន្ត មិនប្រកាន់ពណ៌      សំបុរ ជាតិសាសន៍ឡើយ។

សូមអស់លោកអ្នកអនុមោទនា!

(ចប់)